**AUSTRALIAN EMBASSY**
**PHNOM PENH**

# សេចក្តីប្រកាសព័ត៌មាន

## <u>ប្រទេសអូស្ត្រាលីនឹងជួយក្នុងការនាំខ្លួនអតីតមេដឹកនាំខ្មែរក្រហមមកកាត់ទោស</u>

ប្រទេសអូស្ត្រាលីនឹងផ្តល់វិភាគទានចំនួន៥លានដុល្លាអូស្ត្រាលីបន្ថែមទៀត ដើម្បីជួយបន្តដំណើរការរបស់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការនៃប្រទេសកម្ពុជា ។ ការផ្តល់ជំនួយនេះត្រូវបានប្រកាស កាលពីថ្ងៃទី២១ ខែតុលា ដោយលោក Stephen Smith រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី ហើយថវិការនេះ នឹងចូលរួមក្នុងចំណែកថវិការរបស់អង្គការសហប្រជាជាតិលើកិច្ចការអង្គជំនុំជំរះវិសាមញ្ញ សំរាប់កិច្ចប្រតិបត្តិការក្នុងរយៈពេលពីរឆ្នាំបន្ទាប់ ។

វិភាគទានចុងក្រោយនេះ ឆ្លុះបញ្ចាំងពីការគាំទ្រជាបន្តបន្ទាប់របស់ប្រទេសអូស្ត្រាលីចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា និងអង្គការសហប្រជាជាតិក្នុងការនាំខ្លួនអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់មកធ្វើការកាត់ទោស ។ ប្រទេសអូស្ត្រាលីគឺជាអ្នកគាំទ្រដ៏យូរអង្វែងមួយចំពោះអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការនៃប្រទេសកម្ពុជា ហើយកន្លងមកបានផ្តល់វិភាគទាននូវទឹកប្រាក់ច្រើនជាង ៤លានដុល្លាអូស្ត្រាលី ចំពោះកិច្ចប្រតិបត្តិការនេះ ។ ជំនួយនេះរាប់បញ្ចូលទាំងវិភាគទានកាលពីថ្មីៗនេះចំនួន ៥០០,០០០ ដុល្លាអូស្ត្រាលី ដែលបានប្រកាសកាលពីខែមេសា ឆ្នាំ២០០៨ ។

អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការនេះ ផ្តល់នូវឱកាសជាលក្ខណៈប្រវត្តិសាស្ត្រមួយដើម្បីសំរេចបាននូវយុត្តិធមិជូនជនរងគ្រោះក្នុងរបបខ្មែរក្រហមដ៏សាហាវយង់ឃ្នង។ វានឹងជួយពាំនាំមកនូវជនដែលទទួលខុសត្រូវធំបំផុត មកទទួលទោសសំរាប់ឧក្រិដ្ឋកម្មដែលពួកគេបានសាងនៅក្នុងរបបខ្មែរក្រហម។ ប្រទេសអូស្ត្រាលីស្វាគមន៍ចំពោះភាពជឿនលឿននៃដំណើការរបស់សាលាក្តីកាលពីពេលថ្មីៗនេះ និងលើកទឹកចិត្តឱ្យអង្គជំនុំជំរះបន្តចង្វាក់កិច្ចការនេះបន្តទៀត។

ប្រទេសអូស្ត្រាលីលើកទឹកចិត្ត ប្រទេសកម្ពុជានិងសហគមន៍អន្តរជាតិ ឱ្យបង្កើនកិច្ចខំប្រឹងប្រែងដោយសហការគ្នា ដើម្បីធានាថាការកាត់ទោសនឹងត្រូវបានបញ្ចប់ទាន់ពេលវេលា អនុលោមតាមស្តង់ដារផ្នែកយុត្តិធមិអន្តរជាតិ ដែលអាចទទួលយកបាន ដែលប្រកបដោយភាពត្រឹមត្រូវ និងនីតិវិធីច្បាប់។

*ទំនាក់ទំនងសារពត៌មាន:*

***លោក ម៉ាធ្យូ ដាក់វើស*** *លេខទូរទី៣ : ០២៣ ២១៣ ៤៧០*

ស្ថានទូតអូស្ត្រាលី ប្រចាំទីក្រុងភ្នំពេញ

២២ តុលា ២០០៨